# ច្បាប់ល្បើកថ្មី

៙ អ្នកព្រះភិរម្យ ភាសា អ៊ូ ខ្ញុំ បង្គំនឹកគុណ
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃជាមុន គុណគាប់មហាធ្ងន់
មាតាបិតា ។

ឧបជ្ឈាយ៍ជាធំ កាលចាប់ដៃខ្ញុំ ឲ្យធម៌កេសា
អនុសាវន ព្រះកម្មវាចា គុណគួអត្តក
តាំងសាមសិបបី ។

វិខេបឆ្នាំច ចត្វាស័កក កត្តិកកាព្យថ្មី
លើកច្បាប់ប្រដៅ កូនចៅប្រុសស្រី តូចក្តីធំក្តី
ចូរស្តាប់គ្រប់គ្នា ។

ដ្បិតមនុស្សឥឡូវ យកខុសជាត្រូវ យកទ្ទតាធ្វើជា
អំពើកាក្រក់ ឲ្យកឲ្យក់លើលា ព្រះហើនពានពារ
កាន់មាសកាន់ប្រាក់ ។

៥- អាងព្រើលអាងប្រាជ្ញ អាងកោងអាងកាច អាងកាប់អាងចាក់

អាងជើងអាងដៃ អាងកាយអាងជាក់ អាងគុកប្រវាក់

អាងម៉ាស៊ីនកាត់ក ។

អាងសុទ្ធតែខុស កូនអើយចាំចុះ អាងនោះមិនល្អ

អ្នកគិតឲ្យល្អិត ដ្បិតស្រុកលោកក្រ ប្រមាណដំណ

តទៀតទៅមុខ ។

សាសនាទៅឆ្ងាយ លែងបានសប្បាយ មានតែកើតទុក្ខ

កើតទាន់លោកិយ ត្រូវតែទំនុក ដំណែលអាពុក

ចូរចាំគ្រប់គ្នា ។

អ្នកជឿពាក្យចាស់ ជឿចាំឲ្យណាស់ កុំធ្វើបំពា

អ្នកហ៊ានស្បែកជាប អ្នកខ្លាចស្បែកជា មនុស្សពោរប៉ោហៀ

កុំយកខ្លួនបៀត ។

ឃើញបុកគេល្អ ទោះបីមានក្រ យកគេជាញាតិ

គួររាប់អ្នកក្រៅ ផៅអ្នកឯទៀត រាប់រើសមារយាទ

សុចរិតត្រឹមត្រូវ ។

១០- រៀនបទរៀនបាទ កុំកោងហួសខ្នាត កុំភ្លាត់ហួសផ្លូវ

កុំភ្លើនភ្លេចម៉ែ កុំប្រែហួសផុ ឃើញពស់សក់ស្កូវ

កុំសួរមើលងាយ ។

បន្ទុំអាត្មា ខ្លាចមេខ្លាចបា ខ្លាចតាខ្លាចយាយ

បំរើមហាក្សត្រ ប្រយ័ត្នស្តេចទាយ ពាក្យពិតទំនាយ

រលាយគេក្តីឈ្លោះ ។

ពាក្យស្តេចពាក្យគ្រូ មានប្រែមានប៉ូវ កម្រើកោះ

ជួនទាយឲ្យទាប ជួនទាយឲ្យខ្ពស់ ទាយឲ្យស័ក្តិយស

ទាយបុះកុំខឹង ។

បម្រើមើលគេច ចំណាំព្រះនេត្រ ហេតុខ្លួនឲ្យដឹង
ខ្លួនខ្ជិលហៃហាព្រើល លោកមើលសំឡឹង សំឡក់ឲ្យប្រឹង
ខំប្រិតសូត្ររៀន ។

បម្រើមើលពុត ប្រាជ្ញាឲ្យមុត ស្មារតីឲ្យមាន
បើខ្លៅឲ្យប្រាជ្ញ បើខ្លាចឲ្យហ៊ាន ចង់បានរបៀន
កុំអៀនកុំខ្មាស ។

១៥-ពុតលោកជាធំ ជ្រះឆ្អៅប៉ុនភ្នំ ឯងមើលមិនច្បាស់
បម្រើលោកណា លោកហ្នឹងជាម្ចាស់ លោកស្អប់អ្វីណាស់
ប្រាសចោលឲ្យឆ្ងាយ ។

កុំឈមឈរជិត កុំយកធ្វើមិត្រ ភ្លាត់ខ្លួនអន្តរាយ
បើប្រពន្ធកូន បងប្អូនទៅហាយ អាពុកបុម្ដាយ
ទុនគាយប្រតិបត្តិ ។

អ្នកកុំមើលងាយ ឃើញគេកើកកាយ ព្រួញខ្លួនប្រយ័ត្ន
ត្រកូលញាតិផៅ កូនចៅមហាក្សត្រ ស្មើថ្មើមប្រមាត់
ប្រមាថមិនបាន ។

ទោះអ្នកដទៃ អ្នកព្រៀងអ្នកព្រៃ ដែលលោករាប់អាន
កុំថាតែមនុស្ស ទោះសត្វតិរច្ឆាន ឯណាស្អប់ប៉ុន្មាន
កុំហ៊ានប្រមាថ ។

របស់ប្តទ្រព្យ ដែលជាសំអប់ កុំបាច់សំអាត
ទ្រព្យណាសំឡាញ់ អស់អញឧហាត ចូរចៅសង្អាត
ជួយថែរក្សា ។

២០- កុំផិះកុំផាន់ ស្មោផ្លីអាបម៉ាន់ ពាក្យចាស់ឧបមា
បុរាណហៅផ្លី ពីរបីប្រការ កុំស៊ីត្រង់ណា
ជុះដាក់ត្រង់ហ្នឹង ។

សាច់សាលោហិត កុំផ្តួលផ្តក់ផ្តិត ផ្ទុបភោសកើតប្ដឹង
អាពុកផ្ដែផ្ដាំ ប្ដូរចាំបេះថ្ងៃ សាច់ថ្លើមស្អុយផ្អឹង
និងស្បែកខាងក្រៅ ៗ

សាច់ស្អុយកន្ទុះខ្ទុយ ពុកស្រោបដំបូន ប្រពន្ធកូនចៅ
សរសៃនិងស្បែក ចែកជាញាតិផៅ ខ្ញុំស្រីខាងក្រៅ
ជាស្មៅអាចម៍មាន់ ៗ

ស្រីខ្ញុំកំដរ បើឃើញប្រពៃ កុំលលូកលាន់
កុំល្អួចលបលង ក្រែងម្ចាស់គេទាន់ កុំកប់កុំកាន់
អាប់អន់គ្នា ៗ

បើអ្នកមានយស មានសក្តិខ្ពង់ខ្ពស់ គាប់ទីនគរ
ធ្វើធំធ្វើធី មន្ត្រីមានគ្រា ព្រះហ្ងងទុកញាតិ
សាលាកុង្ស៊ីយ៍ ៗ

២៥- បេះប្លាប់ចាកំង កុំភ្លេចសង្ឃឹម គតភាពខន្តី

កុំធ្វើហួសមាឌ ភ្លេចញាតិប្រុសស្រី ឥន្ទុកាត់ក្ដី

យកទបេក្ខា ។

កុំគាន់សីហាលោ កុំកាន់លោភា ទោសាមោហា

កុំដក់កាកៀន កុំឃ្លានផឹកស្រា កុំស្ទប់ខានណា

សព្វាយកគ្រង់ ។

លួងលោមពីរោះ កុំជេរព្រោធ បញ្ចាលឲ្យបង់

ឲ្យបែកឲ្យធ្លាក់ ពាក្យសត្យពាក្យសង្ឃ កូនអើយផ្ចិតផ្ចង់

តម្រង់ឈ្លោះតេ ។

កុំកើនឃើញប្រាក់ កុំភ្លើតភ្លាត់សេក្ដី ធ្លាក់ទៅអវិចី

កាន់ធម៌មិនសេពគ រតៈទៀងរកសី ឆាប់ពីលោកិយ

ផល់បរលោកគាយ ។

អ្នកក្ដីជាភ្លើង កុំកាត់កាន់ជើង អ្នកម្ខាងមើលងាយ
ចៅក្រមជាទឹក រំពុករំលាយ កុំជេរកុំវាយ
បន្ទំនាំខុស ។

៣០- ចោរខ្ជួចលួចប្អូន រីចោរស្ម័គ្រស្មន់ តណ្ហាស្រីប្រុស
កុំស្អប់ខាងណេះ បញ្ជោះខាងណោះ លួងណោមបញ្ចុះ
បញ្ចូលចិត្តក្ដី ។
កុំផុតឲ្យក្ដៅ បើឃើញគ្នាខ្លៅ ប្រាជ្ញគ្នាខ្លី
កុំឃ្លានប្រាក់ប្រុស បន្ទុះខាងស្រី បើកាន់ច្បាប់ថ្មី
កុំចោលច្បាប់ចាស់ ។
កុំជឿលអ្នកស្រែ ត្រកូលឯងខ្មែរ កុំប្រែក្រឡាស់
ក្រឡេកឃើញគុណ ទន់ខ្លួនសំពះ កុំឆ្មើអ្នកណាស់
កុំត្មះអ្នកក្រ ។

អ្នកកុំភ្លេចគុណ គ្រូលេខនព្វន្ត គ្រូសូត្រអក្សរ
កុំចាប់ដៃទាញ គិឆាប់ង៉ក់ក កុំជជែកត
ស្មើមិត្រសំឡាញ់ ។

ពស្ត្រែត់ចូលជ្រក សួរសាកទៅមក កុំអើងអញ
ពាក្យពុំពីរោះ គេកើតមួកាញ់ គេជៀលផ្ចាលផ្ចុញ
អន្តរាយកេរ្តិ៍ឈ្មោះ ។

៣៤- កុំធ្វើអាងបុណ្យ ស្រដីឲ្យទន់ ពោលពាក្យពីរោះ
ខ្លួនអ្នកនឹងថ្កើង នឹងឡើងសក្តិយស កុំធ្វៀតនាំឈ្មោះ
ញុះញង់អ្នកធំ ។

កុំស្អប់អ្នកកួច បើឃើញគ្នាខូច គួរគិតប្រមុំ
ទោសគ្នាតិចតួច ផ្ទួចឡើងជាធំ ផ្សែងពួកជាជុំ
ផ្តុំចេះជាកើន ។

កុំភ្លើនភ្លេចខ្លួន ចេះសាសន៍ចិនយួន កុំចោលខ្មែរយើង
កុំធ្វើក្រអឺត កុំតឹតកុំតើង កុំពាក់ស្បែកជើង
ចូលវត្តលោកសង្ឃ ។

ដោះមួកដាក់ចង្កេះ ឱនកាយប្រតិបត្តិ លំគុតឱនអង្គ
កុំស៊ីតាមឃ្លាន កុំហានតាមចង់ គាប់ច្បាប់ស្រុកព្រហ្មង្ស
កុំបង់សាសនា ។

កុំចង់ថ្កើងពេក កុំលើកដំណោក បួសមេហួសបុ
តែងខ្លួនឲ្យល្មម មើលពួកពង្សា សង្ខេបនិដ្ឋិតា
រៀនផ្គាប់បុណ្យសក្តិ ។

៤០- បើទៅជាពស្ត្រ ក្រាញវៃឈ្លាស គួរពសខ្ទុកផ្ទាក់
ឲ្យធ្មៀតវៃកពុន បើធួន់សុំផាក់ ទំរកមាសប្រាក់
ឲ្យគ្រាន់ពាន់ចាយ ។

ពជ្យបាពីសែស កូនកុំប្រហែស កុំថ្មមរូបកាយ
ដើរគិតដេកគិត ជួញជិតជួញឆ្ងាយ បើបន់សប្បាយ
ស្រេបនៅមានទ្រព្យ ។

ពជ្យហួសពីមុខ រកស៊ីវៃកពុន មានក្រតាមក៏ពូ
ពជ្យលោកឥឡូវ ត្រូវខំឲ្យញាប់ តែខ្ជិលច្រើនជាប់
ខ្ទោះជើងខ្ទោះដៃ ។

តាំងពីឆ្នាំប ចាំផាំដំណ ទំនិញឡើងថ្លៃ
បងក្បិនឲ្យតឹង ប្រឹងកុំតាំងៃប សញ្ជឹងយប់ថ្ងៃ
កុំឲ្យក្រខ្សត់ ។

បើបន់ស្រាលខ្លួន  រៀនសូត្រឲ្យមួន  ឲ្យមាំឲ្យស្ទាត់
កុំបេះស្ទាក់ស្ទើរ  ល្ងើរល្ងើឥតបទ  បើបេះប្រាកដ
ប្រាក់តែតាមហៅ ។

៤៥- កុំថមកម្លាំង  កាប់ជីកបូកចាំង  កុំជាឆោក្តៅ
រៀនគូឲ្យឆ្អិន  កុំឲ្យខ្លាចនៅ  កុំដេកតែខ្លៅ
ក្រក្រៅសណ្ដាប់ ។

បើល្អន់ឲ្យបេះ  រករៀនតម្រិះ  រិះរកតម្រាប់
ឥន្ទ្រីយធ្ងន់ស្តំ  កុំចាំគេប្រាប់  រៀនស្តីរៀនស្តាប់
រៀនមើលឲ្យស្ដែង ។

កើតមកជាមនុស្ស  ទាំងស្រីទាំងប្រុស  មិនថែលបេះឯង
បើក្រឲ្យមាន  វិញ្ញាណបេះក្រែង  គិតគ្រប់កន្លែង
កុំដេកតែក្រ ។

កុំប្លន់កុំលួច　កុំខ្ជិលកុំខូច　កុហកឆ្វេង
បោកប្រាសយកប្រាក់　ប្រហក់ផាប់ក　កាន់មារយាទល្អ
សុចរិតត្រឹមត្រូវ ។

កូនអើយរកស៊ី　កកាយធរណី　ធ្វើស្រែយកស្រូវ
កុំតាមអ្នកណា　ចាតាមតែឪ　លើកក្ដីជិតផ្លូវ
កុំស្រាស់បន្ទា ។

៥០- គេដើរយប់ថ្ងៃ　មុតជើងមុតដៃ　ដឹងចៀសទៅណា
ចៀសចុះជាន់ស្រូវ　ហើយជេរផ្ដាសា　កូនម្ដាយអាណា
ស្រាស់ដើរមិនរួច ។

កុំយកគល់ឈើ　ទៅដាក់ពីលើ　ទោះធំទោះតូច
ជំពប់ជើងគេ　គេថាឯងខូច　ជេរជៀលផល់ពូជ
ប្រផ្ទូចមេបា ។

លើកក្ដីឲ្យធំ បង្អាប់ឲ្យមាំ គាប់ភ្នែកទេវតា
ស្មើបានសង់ស្ពាន ទឹងមានផលា កើតសាធុការ
អាយុយឺនវែង ៗ

កូនអើយណរណា បើតាមគម្ពីរ ដែលលោកសម្ដែង
កុំចង់បានធំ ប្រមុំធ្មៀលខ្វែង កុំលើកជើងឯង
លបដាក់ស្រែគេ ៗ

អំពើអាក្រក់ មួយចំរៀកសក់ ធ្លាក់ទៅនិរយ
បច្ចុប្បន្នលោកិយ កើតក្ដីភ័យជេរ មិនដែលសុខទេ
ព្រោះដីមួយហត្ថ ៗ

២៤-កុំជួញចង់ពាស ខ្ជួបខាតរបស់ អស់ទ្រព្យសម្បត្តិ
ចង់គន់ប្រយោជន៍ ឲ្យបេះប្រយ័ត្ន ពាក្យមួយម៉ាត់
ឲ្យគិតមួយម៉ឺន ៗ

សំណាកផ្ចិតផ្ចង់ លើកភ្លឺឲ្យត្រង់ កុំលើកឲ្យកោង
អ្នកកុំប្រហែស ត្រែងមានប្រហោង លើកមើលទំនង
ទំនាបទឹកហូរ ។

ចំនួនទឹកស្ទឹង ទឹកព្រែកទឹកបឹង ទឹកវាលទឹកអូរ
អ្នកលើលិចស្រូវ ត្រូវបើកបង្ហូរ អ្នកក្រោមកុំថ្ងូរ
បង្ហូរហួសទៅ ។

កាន់រនាំងថ្ងៃយប់ ឆាប់លើកឆាប់ទប់ កុំឲ្យបាក់ជ្រៅ
កត្តិកចេញខ្យល់ តម្កល់ទឹកនៅ បើចង់បានស្រូវ
ស្រេចនៅត្រឹមថៃ ។

កុំយកគ្រាប់ត្នោត ទៅដាំទៅដោត ពីលើភ្លឺស្រែ
ចិត្តគិតប្រមាណ ចង់បានផ្កាផ្លែ ដាំដុះបន្លែ
បង្ហិនខ្លួនឯង ។

៦០-ផល់ត្មោកឡើងគល់ ឡើងកើតនាំខ្វល់ បានល្អតឡើងវែង

ក្ដរកស់ជាប់ទឹម ក្របីជាប់ស្នែង ខលើសខខែង

ក្ដរក្មេងមិនត្រូវ ៗ

ផល់ត្នោតកំពំ មានស្លឹកវាទុំ វាជ្រុះក្នុងស្រូវ

ស្រែឆ្ងាយពីផ្ទះ ឃ្វាតណាស់ពីផ្លូវ ទំកាំតែទៅ

រលួយស្រូវអស់ ៗ

កូនអើយកុំភោត បើចង់បានត្នោត ដាំដោយកៀនកោះ

ដីទួលចំការ ឯណាបរទ្វោះ ដាំជារបោះ

ជាយផ្លូវរបង ៗ

របៀបចំការ ថែទាំរក្សា យូរ ៗ ស្រាស់ម្ដង

ស្រាស់ឲ្យត្រូវផ្លូវ មើលគួរសមផង កុំបើកមុជឆ្ងង

ទៅស្រាស់ខាងក្រៅ ៗ

មិនគាប់ប្រសើរ របស់កដើរ អ្នកម្ចាស់រក្ដៅ
កើតក្ដីកើតក្ដាំ អស់ខាតអស់ការ ទំនងអស់ញាតិផៅ
ពីព្រោះចំការ ។

៦៥-មួយទៀតរបស់ ដិតផ្លូវអ្នកផង គេទៅណា ៗ
ធ្វើឲ្យខូណាយ កុំកាយបន្ទា កាប់ក្ដឹះ ចាត់ក្ដារ
ឲ្យធ្លាយពីផ្លូវ ។

កុំធ្វើបង្អៀត ក្រែងយប់អធ្រាត្រ ខ្លះមកខ្លះទៅ
ជៀសគ្នាមិនរួច បើកបរកាត់ស្រូវ ជេរម្ដាយតាមផ្លូវ
រហូតដល់ផ្ទះ ។

កូនអើយអ្នកចាំ អ្នកកុំបង្កកម្ម មានពៀរច្រើនណាស់
ជាតិក្រោយខ្វាក់ខ្វិន កខ្វេះកខ្វាស ស្លូវពោលដ៏ខ្វះ
មិនខាតប៉ុន្មាន ។

កុំខ្លាចតែក្រ ធ្វើបុកមិនល្អ ច្រើនកើតទុស្តាន
រអែករអេក បាត់ញាតិសន្តាន ឥតគេរាប់អាន
មានតែគេស្អប់ ។
កាន់បុកឲ្យខ្ពស់ ឲ្យខ្ពើមពាក្យឈ្មោះ ទើបបានជាគាប់
យកគោតដាក់ខ្លួន ច្រើនមានគេរាប់ បើខ្លួនឥតទ្រព្យ
កុំញាប់ហ៊ានខ្ចី ។

៧០- គ្រប់ការសារពើ បង្អរកញ្ញើ កន្តាំងគោល្អី
រនាស់រទេះ គោសេះក្របី បើបានជាខ្ចី
ខ្ចីប្រាក់គេទិញ ។
យកមករកេស៊ី ខែមួយខែពីរ សងប្រាក់គេវិញ
របស់បានយើង ជាដើមដួញចេញ ឯទ្រព្យនោះមិញ
ពេញជាទ្រព្យឯង ។

កុំខ្ចីគេប្រើ  តែមួយដំណើរ  មិនយូរអង្វែង
ជួនជាបាក់បែក ជជែកទាស់ទែង  សងគេមិនលែង
ទាស់ផ្លាស់ជាថ្មី ។

កើតមកជាប្រុស  គិតឲ្យសព្វសុស  កុំឲ្យសល់អ្វី
បួសរៀនធម៌គាថ៌  សាស្ត្រាបាលី  បរលោកលោកិយ
កុំបីបន្ទោះ ។

សឹកមករកស៊ី  កកាយធរណី  ធ្វើជាគ្រហស្ថ
កុហកដៀថុល  បំណុលរុំគោះ  ច្រើនគេដាក់ខ្នោះ
អស់ស្រែចំការ ។

៧៥- ធ្វើពស្ត្ររកស៊ី  ចិញ្ចឹមគោញី  ថែទាំព្យាបាល
ក្រហេតុពីខ្ជិល  មានដៀតខសប្តាហ៍  អ្នកមានច្រាញ់
មិនស្មើគំនិត ។

កំណើតសំណាង សំណូមសូមសាង កកើតពីគិត
ពីកាលជាតិមុន បុណ្យព្រេងអតីត កើតរូបគំនិត
ទើបកើតសំណាង ។

ឯមនុស្សសំណល់ ល្ងង់ល្ងើជឿផ្ទាល់ ទាស់ទែងក្អេងក្អាង
ដប់ឆ្នាំនេះហើយ ប្រកាន់ម្យ៉ាងៗ ខ្លះអួតសំណាង
ខ្លះអាងគំនិត ។

កូនចៅប្រុសស្រី រកប្រពន្ធប្តី ឲ្យរកស្រុកជិត
បើរកស្រុកឆ្ងាយ ឲ្យម្តាយពិនិត្យ ឲ្យត្រឹមត្រូវពិត
ពូជពង្សរាវតារ ។

កូនអើយអ្នកចាំ កុំជឿខែឆ្នាំ កុំជឿតម្រា
ពាក្យក្បួនតម្រាយ កើតពីមនុស្សចាស់ ពីដូនពីតា
ចារតាមសម្គាល់ ។

៨០- អ្នកជឿតែពូជ  អម្បូរធ្លាប់ខូច  ក៏ខូចរៀងរាល់
ពូជមានក៏មាន  ពូជពាលក៏ពាល  កុសលអកុសល
យើងមើលមិនដាក់ ។

ប្រពន្ធនិងប្តី  អាយុវែងខ្លី  យើងមើលឃើញច្បាស់
កុំយកពូជល្បែង  ពូជក្មេងអារក្ខ  បើម្វីបង់ប្រាក់
រកអាយុវែង ។

អម្បូរពង្សពូជ  ត្រកូលធ្លាប់ខូច  ក៏ខូចមិនលែង
ពូជចោរស្រី ៗ  យកប្តីចិត្តឯង  មិនគិតកោតក្រែង
ខ្លាចចិត្តមេបា ។

កូនចៅស្រី ៗ  បើនឹងយកប្តី  ឲ្យមើលកិរិយា
មួយក្មេងអារក្ខ  មួយអ្នកបាណា  មួយអ្នកផឹកស្រា
មួយអ្នកបង់ស្រី ។

មួយអ្នកក្រមាច់ លេងជាមលេងកាចម៌ អាយុច្រើនឆ្នី

ប្រកាច់ផាច់លក្ខណ៍ ជាន់អារក្ខព្រៃ មួយគឹមន្ត្រី

ធ្វើក្រមជំទប់ ។

៨៥- ជំទយតែដើរ មេស្រុកគេប្រើ តាំងថ្ងៃតាំងយប់

មានមួកខ្នះធ័ត្រ កម្រមានគ្រប់ មួយទៀតកុំកប់

ជួញប្រាំប្រការ ។

ប្រាកដជាខុស លក់សត្វតាំងរស់ មិនបេះឥន្ទិយា

សព្វសត្វអ្វី ៗ បក្សីបក្សា ព្រាត់មេព្រាត់បា

ទេវតាលោកលក់ ។

លោកិយនេះខ្សត់ យម្ពុបាលគេកត់ នៅស្ថាននរក

មួយហួយអាប៉ាន់ ប៉ោបៀគ្រប់មុខ កូនអើយចាំទុក

ក្រៃគ្រប់ប្រាំបី ។

ឯអ្នកទាំងអស់ គេស៊ីម៉េះម៉ត់ ច្រើនជាងស្រើ ។
ក្រញាំនោះវែង គំនិតនោះខ្លី ប្រពន្ធជេរស្តី
កាន់ក្បោះបំពាន ។

នេះពួកអ្នកក្រ រស់ទាំងគ្រួសារ ទាំងអត់ទាំងឃ្លាន
ធ្វើគុណទឹងទេ គេគេបង់គ្មាន ហេតុនេះកុំរៀន
ទាំងក្រាំបំផ្លូវ ។

៩០- យ៉ាងអ្នកនេសាទ មិនដែលសង្វាត ធ្វើស្រែបានស្រូវ
ប្រព្រឹត្តសាងកម្ម ប្រចាំវេផ្លូវ វត្តុនខុសត្រូវ
ព្យាយាមសម្លាប់ ។

អន្ទាក់ជង់ក្រុក អង្រុតឈ្នាងឈ្នាក់ គ្រប់គ្រឿងប្រដាប់
ថ្មុកបៀគ្រទាំង ចបប៉ាងចាបចាប់ បោលស្រូវកណ្តាប់
ករណ្ឌៃកាត់ស់ ។

កំពប់ខ្នាត់ខ្វាយ ខូចខាតអន្តរាយ មិនស្តាយស្រណោះ
យប់រវល់ប្រឋក់ ចង់បានត្រីរស់ រែងក្លីរវល់ចុះ
ដើរដេញសំពោច ។

រក់តែសប្បាយ ដើរដេញទន្សាយ ដើរចង់សន្ទូច
អំពើអស់នោះ ប្រើនខ្វះស្រូវពូជ ធ្វើបានតិចតួច
គាន់ជឿគេស៊ី ។

កូនអើយចំណុល ចង់ការជឿបុល មួយឡើងជាពីរ
អ្នកក្មេងការក្ខ ប្រើនទឹមគោញី ធ្វើស្រែមួយពីរ
ធ្វើសោះតែខាន ។

៩៤- ថ្ងៃដេកក្រក្សាក់ យប់លៀងការក្ខ ឈើ្មាលសន្តាន
គេស្តីគេតឹង ខឹងឈប់ពុំបាន គេរកាប់គាន
កាលមានធុរៈ ។

ផ្តុំបុក្កូតក្រុ ស្រែកប្រៀនក់យស្គរ មិនបានលុយកាក់
ឯងពឹងគេវិញ គេគ្មានជំពាក់ ពឹងបានម្នាក់ ៗ
ដោយសារឲ្យថ្លៃ ។

ទៀងត្នោតក្ដួរស្រែ កម្រទាន់គេ ដ្បិតដេកដល់ថ្ងៃ
ប្រូតកាត់បង់ចាប់ ជួលគេពេញថ្ងៃ ចំណេះចង្រៃ
មាំខាតក្ដីការ ។

ឯខ្លួចការក្ត ស្លាប់ជាប់រស់ម្នាក់ ថ្វាយបោកថ្វាយស្រោ
សំពះទឹកគុណ ខ្លាចប្រូតជូនតា មិនផ្ដើលអ្នកណា
ទឹកគុណអ្នកក្មេង ។

ឯអ្នកប្រមឹក ប្រូបូលកនផឹក ភ្លើកៀនទឹងក្មេង
សំដីប្រើនតឹង ស្រាំងវង្វេង ជំហរអ្នកក្មេង
មិនរបះក្រខ្សត់ ។

១១- ស្អូតហ៊ាំងបំពាន ផឹកម៉ៃលុយមាន ផឹកម៉ៃលុយអត់

ឯកវេះតែកិច ប៊ិនវេះតែកត់ ផឹកដល់កំណាត់

យកស្រែបញ្ចាំ ៗ

សល់ផ្កាលមួយពីរ ភ័យគោស្លាវស៊ី មិនគិតខ្លាចកម្ម

ផឹកស្រុលហួសល្បត់ អត់បាយភល់នំ ហស់ស្រែបញ្ចាំ

បញ្ចាំកូនទៀត ៗ

កំណើតផឹកស្រា ផឹកផុតមេត្តា ផឹកស្រូលហួសមាត់

អ្នកមួយផឹកស្មើរ ល្វីល្វើរតែទៀត ម្សៀងផឹកផុតមារយាទ

ច្រើននៅទុំបិន ៗ

វែកចឹកពុះទុស ពំទុញពាត់ ហក់វៃផឹកសិន

ស្ទើរវែកទឹកអត់ សំពត់ខើចក្បិន ទំពាំយម្ចិន

បិនផ្លូសហៅស៊ី ៗ

ទាញកៃម្នាក់ឯង  ខ្ទួតហើយទំស្លែង  ទំលើកទំលើ
ផងទឹកស្រោចគ្រប់  ស្រោចខ្ទឹមម្ទេះដើរ  ខ្ញុំចិនម្ទៃពីរ
វិលទៅរកំងផ្ទះ ។

១០៩· ឯអ្នកចង់ស្រី  ប្រពន្ធពីរបី  ចាំឯងអ្នកណាស់
គន់ឯសំពត់  តែមួយបន្ទាស់  ពាក់អាវបំណាស់
កម្រមានថ្មី ។

ផ្ទះលេចភលើង  ជញ្ជាំងកង់ហ៊ីង  ស្លាធ័រពាយស៊ី
ខ្លួចប្រេងក្រមួន  ម្សាបារី  កំឡោះពីរបី
ពោមពោមរៀនស្នេហ៍ ។

រៀនស្លាបរេនស៊ិច  កើតក្តីពីក្តិក  ព្រាយចិត្តម៉ៃ
កូនហើយប្រពន្ធ  រាងបន្តពូកៃ  គ្រូវគុកជាប់ខែ
អស់ស្រែគ្រពាំង ។

ធម្មតាប្រពន្ធ   បានដោយសិល្បមន្ត   ដោយស្ងាត់កំបាំង

រកស៊ីលៀនក្អែក   បានរែកខ្ទះឆ្នាំង   បានល្អិតន្តាំង

នៅខ្ទះចង្អើរ ។

បាននេះខ្ទះនោះ   ក្រហេតុតែព្រោះ   អាពុកម្ដាយជេរ

បើចូលដីខ្ញុំ   មិនរម្យដូចគេ   អន្ទិយេះវេរ

មិនហ៊ានហាលមុខ ។

១១០-នេះពុតអ្នកក្រ   ចាំជាតំណ   តជាចំនុក

ប្រយ័ត្នដំនៀល   គេរៀលអាពុក   កូនអើយចាំទុក

ចាំតកូនចៅ ។

ត្រកូលពូជពង្ស   បើខ្លួនល្មើតល្មន់   ស្ដាប់ចាស់ប្រដៅ

កុំស្អប់អ្នកប្រាជ្ញ   កុំខ្លាចអ្នកខ្លៅ   បើមនុស្សឆោតឆៅ

កូនឯងកុំគប់ ។

កុំភ័យខ្លាចអត់ មើលឲ្យប្រាកដ គួរយកគួរឈប់
គួរឈានគួរឈាន តោងមើលឲ្យគ្រប់ កុំចេះតែឈប់
មិនស្គាល់ឪម៉ែ ។

រកប្ដីប្រពន្ធ ឲ្យគិតឲ្យគន់ ឲ្យមើលជួនថែ
ត្រកូលក្រខ្សត់ ប្រាកដតាមខ្សែ បីដូចឈើផ្លែ
មិនដែលចេះក្លាយ ។

ជូរផ្អែមធំតូច ដើមក្រូចផ្លែក្រូច ដើមស្វាយផ្លែស្វាយ
ពូជស្រីចោរក្បត់ មិនអត់សាហាយ ពូជស្រីមេម៉ាយ
ពីម្ដាយដល់កូន ។

១១៩- រើសពូជមិនខុស ពូជសាំងនឹងប្រុស តាំងអស់ជំនួន
ពូជសែនមេបា ពីតាដល់ជួន ពូជល្អស្អុចស្លូន
ពីជួនដល់ចៅ ។

រករូបមិនក្រ    តាក្រក់ហើយស    មារយាទល្អហើយខ្មៅ
ស្រីក្មេងមានខ្នាស    ចាស់ចង់ប្រដៅ    ប្រដូចតាមដៅ
មិនសូវខុសរាមន    ៗ

ពាក្យចាស់លោកថា    ធ្វើស្រែចំការ    ស្ដាប់មហាសង្ក្រាន្ត
ធ្វើម្ដងខុសខាត    ធ្វើម្ដងទៀតបាន    ធ្វើតាមប្រមាណ
ប្រមើលទឹកភ្លៀង    ៗ

រកប្ដីប្រពន្ធ    ឲ្យគយឲ្យគន់    រើសរករូបរាង
ពូជថ្លៃល្អយក    ពូជថោកល្អមរាង    រូបល្អពុកល្អៀង
នាំកុំប្រសព្វ    ៗ

ជាតិស្រីនិងប្រុស    បើបានជាខុស    ខុសកាលចាស់ងាប់
បើបានរូបល្អ    កម្រមានកំពូ    មានខុសមានគាប់
ដូចស្រែចំការ    ៗ

២០- មួយទៀតអ្នកតាំ  អាពុកបំណាំ  ទុកជាតម្រា
កុំយកតម្រាប់  កុំស្តាប់អាចារ្យ  បើនឹងរៀបការ
កុំការប្រជួន ។
ប្រថែងវេលា  ពុស្គរឆ្លើយគ្នា  ប្រទប់ប្រទួន
ស្រុកជិតកូមិនផង  របងដោយខ្លួន  អាចារ្យអាងក្បួន
ជាសុខសប្បាយ ។
កូនអើយអ្នកតាំ  យូរណាស់ឆ្នាំ  ព្រាត់ប្រាសអន្តរាយ
ច្រើនស្លាប់ ៣ នាក់  រស់ម្នាក់មេម៉ាយ  កូនឃើញតែម្តាយ
មិនឃើញអាពុក ។
មានកាលស្លាប់ស្រី  ស្លាប់ពោលកូនខ្ចី  ប្តីនៅរងទុក្ខ
យកប្រពន្ធទៀត  តម្រាពេញមុខ  កូននិងអាពុក
បែកគ្នាខ្វាត់ខ្វាយ ។

កូនចៅស្រី ៗ បើនឹងយកប្តី កុំយកពោះម៉ាយ

សូវនៅម្នាក់ឯង បន្ទន់នឹងម្តាយ អាណិតរូបកាយ

ស្តាយខ្លួនក្រមុំ ។

១២៩- ហៅប្រុសអកតញ្ញូ ប្រពន្ធដើមស្លាប់ មានកូនតូចធំ

យកឯងជាកូន បំរើតែយំ ច្រើនឈ្លោះជំនុំ

ព្រួយចិត្តម៉ែឪ ។

ហៅប្រុសចិត្តពីរ ពិបាករកស៊ី រញ៉ាំរញ៉ូវ

ឯងធឿយស្មើរស្លាប់ ផ្គាប់ចិត្តមិនត្រូវ បីបួនរដូវ

ខ្លួនឯងស្លាប់ទៀត ។

ចរិតខាងប្រុស កូនអើយចាំចុះ កុំយកខ្លួនបៀត

ស្រីណាទំលាក ស្រីពោះបង់មារយាទ ប្រុសព្រួយខ្ចប់ជាតិ

ខ្ចប់គ្រប់ជាបី ។

យកទៀតជាប្អូន គ្រោះដល់ស្លាប់ខ្លួន មេម៉ាយខាងស្រី
ប្រាកដមិនខុស ប្រុសក្នុងលោកិយ ស៊ូនៅតែប្តី
ស្លាប់រស់រូបមួយ ។

បើខ្លួនកំព្រា រំពឹងមីងមា រកស៊ីមិនព្រួយ
កាន់មារយាទល្អ មិនក្រគេជួយ បងប្អូនកូនក្មួយ
គេបបួលឲ្យប្រើ ។

១៣០- ពោះម៉ាយមានប្តី កុំយកធ្វើប្តី មិនគាប់ប្រសើរ
អាមួយស្រីលែង ស្រីគេគ្រាន់បើ ពោះម៉ាយក្លាយដើរ
អាងលែងប្រពន្ធ ។

ពោះម៉ាយតាំងអស់ កុំយកឲ្យសោះ ហៅប្រុសទុរជន
ទុរជាតិអប្រិយ ស្រីកើតទុក្ខធ្ងន់ ហៅមួយជំនាន់
ចំណាំមិនខុស ។

កុំឡោះពាស់យូរ ពាស់ទុំគេគ្គូ ល្មមព្រមយកចុះ
រកស៊ីមានបាន សុខសាន្តឥតឈ្លោះ ចំរើនរូបរស់
អាយុយឺនយូរ ។

កុំយកប្តីប្អូន ថោកកសិខ្លួន រកស៊ីមិនជួរ
គេហៅឯងធំ សមហៅគេតូច ច្រើនខ្ជិលមូចូ
ម៉េះមស់ទឹងល្បែង ។

អាច្រើនមើលងាយ ហៅស្តីឱយាយ់ ហៅបាន់ហៅឯង
ខ្លួនយើងជាស្រី ស្រដីឥតក្រែង យល់គេប្អូនឯង
ឯងមើលងាយដេរ ។

១៣៥- ពាក្យពាស់លោកចង់ ប្តីទុកស្នើបង់ ប្រពន្ធស្នើម៉ី
មើលងាយកល់ថ្ងៃ បង្រែកល់ខែ រកស៊ីធ្វើស្រែ
ច្រើនខាតគ្រាប់ស្រូវ ។

គួរយកប្ដីបង់ ពាក្យបាស់លោកបង់ ទុកប្ដីស្មើឪ
ខ្លួនឯងប្រមាថ ប្រតិបត្តិឲ្យត្រូវ កសីគង់នៅ
ទេព្រក្សរក្សា ។

ប្រពន្ធទិន្នប្ដី ធំស្រេចទីន៍ស្រី គត់គង់កិរិយា
ឈ្មោះហើយប្រើឲខ្សូត់ ស្រីអត់លក្ខណា ប្ដីខ្ពិលទុស្សាហ៍
ព្រោះប្ដូកប្រពន្ធ ។

ជាតិស្រីមានលក្ខណ៍ ទេវតាតំទាក់ កបកើតទ្រព្យធន
ប្រទេបជេរក់យ បប្រែទុរជន ដួជាតិលើសលទ់
លើសលុបលើប្រុស ។

ហៅកាឡកិណី ក់យកូនជេស្ដី មិនដឹងត្រូវខុស
បើមានភ្ញៀវមក រំពរពឿងឈ្មោះ អាសោចសាយសុស
រន្តោះធនធាន ។

១៨០-រកស្រីមារយាទខ្ពស់ បេះទ្ដើមពាក្យឈ្មោះ បេះត្រាំអត់ឃ្លាន
បេះស្លូតបេះកាច បេះខ្លាចបេះហ៊ាន បេះខ្មាសបេះអៀន
កាចមានប្រាជ្ញ ។

កូនចៅស្រីប្រុស បំណាំទុកចុះ ទុកជាតម្រា
គួរយកតម្រាប់ គួរស្តាប់ពុទ្ធដីកា ព្រះអង្គទេសនា
គាថាបួនបទ ។

រៀនគ្រាប់អ្នកប្រាជ្ញ បើចង់ឈ្នះកាច យកស្លូតសង្កត់
ចង់ឈ្នះមនុស្សរឹង ឲ្យប្រឹងទំអត់ កុំជេរកុំតបត
កុំស្បួចលែងខឹង ។

ចង់ឈ្នះអសុរកះ ស្តីលេងឡេះឡោះ កុំធ្វើជាជឹង
បើងស្តីត្រង់ណា ឲ្យចំត្រង់ណាហ្នឹង ឃើញបុកយើងរឹង
ខ្លាចយើងខាងក្រោយ ។

ចង់ឈ្នះកំណាញ់ ក្រដេក្រដាញ់ សុំអ្វីមិនឲ្យ
បើបានចំណី ហុចកាញយ ៗ តិចដោយច្រើនដោយ
កុំតែកដង ។

១៤៥- នេះមន្តព្រះពុទ្ធ ប្រាជ្ញាឲ្យមុត ឲ្យគិតថ្លឹងថ្លែង
កុំកាចខុសខ្នាត កើតទាស់ផ្សិតខឹង កូនអើយខំប្រឹង
កាន់ច្បាប់ទាំងប្អូន ។

កុំផ្ទួញរវល់ កុំតប់រវល់ កើតទាស់កុំគួន
កូនណាកាន់បាន កូននោះសុខខ្លួន ពេលទាស់លែងដួន
លែងជួបមួយជាតិ ។

បើមនុស្សវៃកុល មកនៅចំកណ្ដាល ពោះញាស់ញ្ញាតិ
ឲ្យមើលលៃលក កុំយកខ្លួនចៀត រំខូលទៅទៀត
អសារឥតការ ។

ចំណីចំណុក បើឲ្យស៊ីចុក ឲ្យដោយមេត្តា
កុំឲ្យជឿរឺ ក្រែងខុសសន្យា កើតទាស់កាលណា
រើរែករត់បាត់ ៗ

មនុស្សគ្មានកន្លែង ខុសពីមារយាទឯង មិនប្រុងប្រយ័ត្ន
តាមតាន់តឹងទារ រាទឹងក្តៅក្តាត់ កុំគួនដោយស្ងាត់
បំភ្លាត់ឯងបាន ៗ

១៨០- ហេតុនេះគួរគិត គួរកូនពិនិត្យ ច្បាស់សុំកប់អាន
គួរឲ្យសឹមឲ្យ គួរខានឲ្យខាន ជៀតពាក្យបុកយោ
មានពីរចំណែក ៗ

បន្ទុកជាក្បួន ចិត្តល្អក្រខ្លួន នេះពាក្យមួយបែក
មួយទៀតចិត្តល្អ មិនក្រយូរពេក ឆ្នាំនេះឆ្នាំស្អែក
ក្តន៍តែទីងមាន ៗ

ចិត្តល្អក្រខ្លួន　ចាំទុកជាក្បួន　ជាក្បាលនិទាន
ឃើញអ្នកទុរគត　កំសត់អត់ឃ្លាន　មិនស្គាល់ពោះវៀន
ហ៊ានឲ្យជឿខ្ចី ។

ទៅតាមមិនឲ្យ　តឹងតឿនញយ ៗ　ទឹងប្តឹងកើតក្តី
ទាតទាំងទ្រព្យចាស់　អស់ទាំងទ្រព្យថ្មី　ស្គមគោក្របី
រលស់ក្តីខានថៃ ។

ចិត្តល្អមួយទៀត　មេត្រីជាញាតិ　សំដីខ្លីស្រែ
បានស្រូវស៊ីស្កប់　គ្រប់ឡប់ជាប់រៃ　រំលងឆ្នាំ១
ដកហូតមិនបាន ។

១៩៤- ឯងប្តីផង ត　ក្តីពាល់តែក្រ　អស់ឆ្នាំងអស់ចាន
របស់កំខាត　របរកំខាន　ដីធ្លីអស់ប៉ុន្មាន
ទុកំពាញ់ឈ្នះ ។

ទ្រព្យធនអ្វី ៗ ចង់ការផ្ញើទុ៎ មើលមុខឲ្យច្បាស់
កុំហោលបញ្ចប់ខ្វែរ កុំភ្លេចពញ្ញក់ព្រះ តាមតែប្រទះ
ប្រុចញ្ញសក៏ខាង ៗ

កាចិត្តកណ្តាល បើនឹងឈ្នាល សប្បុរសមើលហើង
រៀនសូត្ររៀនប្រាជ្ញ កាចកុំភ្លើនភ្លាន់ ក្រែងគ្រោះសំណាង
ខ្លាចនានក៏ស្ងប់ ៗ

ល្អមិនព្រមយូរ ស្ងេនរៀនរគ្រ. ស៊ូកុំស្តាយទ្រព្យ
គ្រប់យកកុំចឹង ឲ្យប្រឹងទំផ្គាប់ ចេះមន្តសាយសព្ទ
ត្រឡប់ជាមាន ៗ

ចម្ពាគ្នាកះចេះ អ្នកស្ងន់ចំណោះ ចេះផ្សិតទំរៀន
ធ្លាក់ទូវក្បួរគ្រាប់ ហាប់សិល្បរបៀន អ្នកខ្សត់អត់ឃ្លាន
ព្រោះចិត្តអាក្រក់ ៗ

១៦០-ខ្ជិលរៀនខ្លៅ　គ្រូដៅប្រដៅ　ខឹងលេងសំឡុក
រពេញរពុញ　ក្បុកក្រុបាក　ស៊ីប្អូនល្អកទក់
មិនខំធ្វើស្រែ　។

អ្នកប្អូនអ្នកល្អប　ធក់បានតិចតួច　បានគ្រាន់បើដែរ
ផលគេឃើញមុខ　ត្រូវទុកច្រើនរៃ　ការក្រក់ផលម៉ឺ
ខ្ញុំបរក្តីផលល់　។

បង់ខ្លួនបានតាប　ជាបើងចង់ណាក　រំភើបក់ធនទៅ
ពាក្យពីបុរាណ　លោកតាទូន្មាន　ប្អូកមនុស្សតឿវ
ត្រូវតាមតម្រាយ　។

អ្នកល្អបអ្នកប្អូន　បង់បានប្រពន្ធ　ពេញចិត្តស្រុកឆ្ងាយ
ចិញ្ចឹមមេស្រុក　ស្អុកធ្វើទៅហ្វាយ　បង់ភ្លើងសប្បាយ
កាយព្រាត់ពជការ　។

ចបាំងចំបាត់ លួចបាទដោយស្ងាត់ អាងមានប្រាជ្ញា
ក្រឡេចឡើងវៃ កាឡៃបោះក្រោ ចាស់ក្លែកទេវតា
វេក្យាផែនដី ។

១៦៤-មួយទៀតទុរជន ធ្វើបាបបានបុណ្យ គឺបុណ្យមន្ត្រី
ទោសទៅចង់បាប កាប់ឥតប្រណី បានបុណ្យមន្ត្រី
ព្រោះបុណ្យធ្វើបាប ។

អំពើទាំងអស់ កុំសាងឲ្យសោះ ចៀសវាងឆាយ
កាន់សីលព្រះពុទ្ធ ឱនលុតលួនក្រាប បើក្រដុនងាប
មានទេវតាជួយ ។

កូនអើយទេវតា ស្ថិតសព្វព្រឹក្សា រង់ការជួយ
មនុស្សប្រុសស្ត្រីស្បា ឯណានីមួយ ទេវតាពុំជួយ
ចំណាំស្គាល់មុខ ។

មិនដែលកំពុំថ  កជការបាកំង  គេចាប់ដាក់គុក
ដល់ខ្លួនស្លាប់ទៅ ទៅរងហោយទុក្ខ ហោយទោសនរក
ទាំងពីរកន្លែង ។

នរកបាកំង  មានខ្សោយមានខ្លាំង  មានខ្លីមានវែង
នរកយមបាល  គេផ្តាលឥតក្រែង  ព្រះអង្គសំដែង
ថាលានកោដិឆ្នាំ ។

១៧០- ហេតុនេះគួរកង  គួរហាលគួរកង  គួរចងគួរចាំ
គួរកុំធ្វើបាប  ដរាបខ្ជាបកម្ម  គួរកាន់សីលប្រាំ
បណ្ដាំសាសនា ។

ហៃកូនចៅអើយ  ក្រឡាប់អស់ហើយ មិនដូចដូនតា
ភ្លៀងជន់ខែប្រាំង  កំងខែវស្សា  ឆ្នាំវិករកា
ត្រីស័កនេះឯង ។

រនោចផល្គុន　　កោតមុន　　ឯកស័កជាក់ស្តែង

ក្នុងខ្មើតផល្គុន　　ជន់គ្រប់កន្លែង　　ទាំងគេទាំងឯង

ធ្វើស្រែបានផល ។

ឆ្នាំរោងឆស័ក　　វិសាខភ្លៀងធ្លាក់　　ពីរកេចសំគាល់

យប់ថ្ងៃអាទិត្យ　　ផនឹងព្យុះខ្យល់　　ភ្លៀងជន់ពេញថ្នល់

ពេញកលតូចធំ ។

ពេញអូរពេញជ្រោះ　　ដើមឈើទាបខ្ពស់　　រលុះរលំ

ចូលស្រុកយើង　　លើងទាំងគុម្ព　　ទើបគ្រាប់ភ្ដុំ

ផ្ដួចដុះជាថ្មី ។

១៧៥-ឆ្នាំបកូរជូត　　កំរើរហូត　　គ្រប់ឆ្នាំទាំងបី

កើតទាំងដម្បី　　ស្លាប់មនុស្សប្រុសស្រី　　ខាលហោះអស់ភ័យ

ធ្វើស្រែស្រូវបាន ។

ភ្លៀងឆ្នាំម្សាញ់ លើដក្បាលគ្រាញ់ ត្រូវតាមបុកណា
កក្តិកដន់កាល ពលសព្វស្មាន អ្នកស្មឹងប៉ុន្មាន
រលួយស្រូវអស់ ។

ដាច់ជួលខាន់ដើរ ពដការគេប្រើ ចាំងបាស់កំឡោះ
មមៃមរធកម្ម បញ្ចុំកេក្តុំកោះ គ្មានអ្នីស៊ីសោះ
ដាប់ពោះក្សិណក្ស័យ ។

ខែបេត្រឆ្នាំវក ស្រឡះពពក កើតមានសម័យ
ជាហេតុអស្ចារ្យ សុរិយាល្អាចថ្ងៃ ឧត្បាតចង្រៃ
ឃើញសត្វក្អើបោះ ។

ពីជើងទៅត្បូង ចាស់ក្មេងមើលប្រូង បានឃើញទាំងអស់
មើលមិនស្គាល់ជាក់ ធ្លាក់ចំបន្ទោះ បាត់ឈឹងស្ងួតសោះ
មិនដឹងទៅឯណា ។

១៨០- កាលមុននោះមក ខែបុស្សឆ្នាំរក លែងមាន អាជ្ញា(១)
មានតែមេស្រុក វាស់វែងក្រឡា ដីមួយហិតា
ស្រូវសែសិបថាំង ៗ

រង្វាន់មេស្រុក ត្រូវហូតមួយចុក ជប់ជូនបាកំង
ទៅដល់ប៉ុយរ៉ូ បញ្ចូរដាក់ឃ្លាំង ពូជពីរកន្តាំង
ក៏ជាប់ពន្ធដែរ ៗ

គ្មានធ្នូរគ្មានតឹង កូនអើយខំប្រឹង ជាតិឯងជាខ្មែរ
ក្មេងប្រុសធំទំ នៅក្នុងផ្ទៃម៉ែ កជការប្រិតប្រែ
ថាឲ្យបង់ប្រាក់ ៗ

កូនចៅប្រុសស្រី កើតមកលើដី ខំរកលុយកាក់
បានហើយប្រឹងខំ ផ្សំគ្នាទុកដាក់ គ្រាន់ទិញស្លៀកពាក់
បង់ថ្លៃរាជការ ៗ

(១) អាជ្ញាហ្លួងពន្ធស្រូវ៖ អាជ្ញាហ្លួងអ្នកទាយផលស្រូវហើយហូតពន្ធ

ភក្រូបទទ្ទាំប ចាប់គោឡោស ដុតដែកពោះក្រោ
ដល់កូរជូតធ្នូវ ជំរូវយ៉ាងណា ទីងកើតឥស្សារ្យ
រហូតកលំឆ្នាំ ។

១៨៥- នគរក្បើនប្លែក សុប្បាយតៃក្លូក ក្នុងចិត្តរើគម្លុ
កូនប្រុសបណ្តាច់ កុំក្អេចបណ្តាំ កប្បាសសូត្រឆ្នាំ
ត្រីម៉ាំលែងដោក ។

ជូនស្វាគំពៅ អំបិលស្ករស្រូវ មានទៅមានមក
មានចុះមានឡើង កស្ត្រាយើងល្អមរក ល្អមរកលែលក
គួរយកគួរខាន ។

កប្បាសទិនផ្ចាំ គួរផាសជីផាំ ភ្លើដៃឯងបាន
កុំសានជួលពេក កុំដេកឈប់ខាន កុំហោលចុកណា
ម៉ែទុជូនតា ។

ជីកេរគេរគោក កុំកាន់ខ្ជិលដេក ទៅឈ្លាតចិនផ្សារ
កូនចៅស្រី ៗ ទំរៀនធ្វើការ បើគ្មានប្រាជ្ញា
មានអាក់បេះស្តី ។

ឲ្យស្លូតបាស់ ៗ រៀនបោះកប្បាស ថ្វេចម្លូរសំឡី
រៀនកូររៀនការ ត្រសារពាក់រវៃ ហូលគោមតាតក្តី
កុំបីបន្ទោះ ។

១៩០- រៀនថ្ពរៀនត្បាញ ឲ្យបាស់បង្ហាញ បង្ហាត់ទាំងអស់
សំពត់ថៃបង់ម៉ឺយ លាយស្បូត្រអម្បោះ កុំទិញគេះសោះ
ឈ្មោះការជាស្រី ។

ទិញដូរតែល័ក្ត(១) អញ្ចុលបេសពាក់ ព្រហូតដាប៉ី
ធ្មេញឈើឈ្នាន់ផ្សំ ក្តារម្ហូរក្តារកី ត្រល់ខ្នារឬស្សី
មុខប្តីជាប្រុស ។

---

(១) ល័ក្ត ផង់ស្អិតឬកកើតជាដុំ មានពណ៌ផ្សេងៗ សម្រាប់ប្រើជាគ្រឿងជ្រលក់

តាំងពីធ្លាប់ ការស៊ីក្រ ៗ ខំរៀនទៅចុះ
ចាន់មានបាស់នៅ ស្គាល់ត្រូវស្គាល់ខុស ចាស់ស្លាប់រលស់
គ្មានមនុស្សប្រះដឹង ៗ

រកស៊ីឲ្យញឹក ដេកយប់លើក រឹតក្បិនឲ្យតឹង
បើភ្ញាក់កាលណា កាន់ការគាលខឹង កូនអើយខំប្រឹង
ទាំងប្រុសទាំងស្រី ៗ

រមៀតស្លឹកគ្រៃ ជីរម្ទេសខ្ទឹមខ្ញី មានដីដាំចុះ
ដាំដើមស្លី ៗ ចំណីគ្រប់ឈ្មោះ គ្រឿងស៊ីឆ្អែតពោះ
ជុះពេលទទេ ៗ

១៩៥- ជុះទិសខាងជើង ជុះដាក់ដីយើង កុំជុះដីគេ
កុំជុះដាក់ផ្លូវ ត្រូវមាត់ក្មេងជេរ ដីសល់ទំនេរ
ល្មមមោកជុះទៅ ៗ

សក់មួយជាដប់ ជ្រៀតសិតឲ្យសព្វ កុំឲ្យសល់នៅ
បើច្រាច្រាក់ ចាក់បិត្តឲ្យជ្រៅ ដាំបេកអំពៅ
ដូរស្រូវគង្ករ ។

កើតមកជាមនុស្ស មួយព្រួយចង់រស់ មួយព្រួយចង់ល្អ
ពីរនេះជាធំ រនាំឲ្យក្រ ចាំជាតំណ
តជាទំនុក ។

មនុស្សមារយាទមិនប៉ិន កូននៅខ្ញុំចិន ព្រោះម្ដាយឪពុក
ធ្វើស្រែមិនត្រូវ គ្មានស្រូវជង្រុក កូនអើយចាំទុក
នេះមុខមេក្រ ។

មេ ១ ជាធំ កំឡោះក្រមុំ ស្លៀកពាក់ចង់ល្អ
បើបានបែបខ្មៅ ចាទៅបែប ស ទើបគ្រាន់អន់ក្រ
ត្រដរចង់ក្តើន ។

ក្រឡាប់ចគរ រំដេរំគកើតហារ ច្រើនឡើងច្រើនឡើង

ពាលរឹងក្រអើត បើកម៉ើតបើកម៉ើង ក្រដាសយ៉ាងស្តើង

ចាយរហែកនៅដៃ ។

ប្រាក់ចាស់អស់ទៅ ព្រោះមនុស្សឥឡូវ ចក្បាតបច្រៃ

ជាតិខ្មែរប្រែះកម ក្រខ្សត់ក្រខ្ស ក្រឡាស់សាសន៍សៃយ

សព្វសត្វនានា ។

ជាតិខ្មែរប្រែខុស ស្រីកូនក្មើប្រុស ប្រុសកូនក្មើជា

យកប្តីប្រពន្ធ មិនស្គាល់មីងមា បុណ្យពានការការ

កាប់គ្នាឥតក្រែង ។

លួងថុកក្មេរបេះ គោបង្គ្រតដាក់សេះ ប្រុស ១ ផុះស្នួន

ស្រីពាក់អាវខ្លី ប្រុសពាក់អាវវែង សារុងហៀវកែង

ភ្លើងឯងស្អកគ្រាន់ ។

កាន់ចិត្តស៊ីបាឡោ សេះទឹមទឹងគោ ចាក់ហ៊ីឡាត់ៗ
រកស៊ីមួយថ្ងៃ ចន់បាឧមួយពាន់ ឋះគោដល់មាត់
តាក់កាប់ដាប់គុក ៗ

៤-រីល្បែងទៀប៉ា ច្រើនទៅជាហោ ប្រកាសហាមគុក
ប្អូនកូនប្រយ័ត្ន ប្រយោជន៍ទៅមុខ ចាំជាទំនុក
តំណកូនចៅ ៗ

អ្នកកុំប្រហែស កជការនិទេស កំចាក់បញ្ចោះចៅ
រាជការសាលាភ ខំប្រឹងប្រជៅ កុំលោភល្ងង់ខ្លៅ
បោកផៅត្រកូល ៗ

ប្រយ័ត្នក្រែកក្រ ផ្លូវច្បាប់ល្អៗ អ្នកខំប្រមូល
ផ្លូវវៀចអាក្រក់ អ្នកកុំដើរចូល ហៅផ្លូវមិនស្រួល
លច់ផុតគំនិត ៗ

ដើរផ្លូវកណ្តាល ស្រឡាញ់សិទ្ធស្មោះ ឈរឲ្យទៀងត្រង់

មគ្គផលសីលទាន ឈានចូលឲ្យជិត យកធម៌ជាមិត្ត

មិនឥតអំពើ ។

មនុស្សម្នាក់ច្រើនទោស ច្រើនគ្នាគេកោត ឈឺគ្មានគេមើល

ស្លាប់ឥតគេព្រួយ គេជួយតាំងស្មើរ មិនដែលទៀងលើ

ប្រមុះចុះក្រោម ។

២១០- កូនចៅស្រី ៗ ក្រមុំសាវខ្ចី រៀនពោតឲ្យល្មម

ប្រុសស្មើរម៉ែឪ ធ្វើធ្ងប្រលោម មើលរូបមើលឆោម

កុំព្រមដោយងាយ ។

កុំគិតភ្លក់ភ្លាញ់ បើចិត្តស្រឡាញ់ កុំចេញនិយាយ

បើស្អប់កុំប្ដឹង បើខឹងកុំក្ដាយ កុំរះកុំកាយ

កុំងាយត្រូវស្បថ ។

កុំដើរប្រាប់គេ    កុំកានអួតដេរ    ក្រែងប្រុសឈឺចិត្ត
នៅឡែតទឹង    កុំរវល់ធ្វើស្និទ្ធ    ប្រុសទឹងកាណិត
គិតចូលដណ្ដឹង    ។

បើបើផុតឡើ    មើលមុខមើលក្រោយ    ការក្រក់ខ្មៅធ្មឹង
ប្រកែកដោយស្ងាត់    កុំខ្វាចម្ដាយខឹង    កើតកូនមកតឹង
ពិបាកបាយណាស់    ។

កុំឃ្លានចំណី    កុំខ្វាចអត្ដី    កុំភ័យខ្វាចចាស់
មើលមុខឯងផង    កុំរើសឥតខ្មាស    ខ្លួនល្អស្រឡះ
មិនខ្វះគេស្ដី    ។

២១៥- បើបានជាខូច    ចាប់ផ្ដើមនៅតូច    ខែពីរខែបី
រវៀរះហើយប្រញាប់    ប្រាប់គ្នាស្រី ៗ    កុំលាក់ធ្វើអ្វី
ក្រែងតែគេជឹង    ។

កុំមាយាបេះក្រុប មារយាទបេះកែខុប មាត់បេះតែខឹង
គេថាត្រង់ណា ដេរគេត្រង់ហ្នឹង ដេរហើយទំប្រឹង
យកប្តូសក្តិ ៗ

រំលាយរំលួត អាក្រក់តែគួច អួតល្អតែមាត់
មានគេឃើញច្បាស់ ម្នះរឹងប៉ិនស្បថ ទោសនេះមិនគ្នាត់
ធ្លាក់ទៅអវិចី ៗ

ពោរគាថល្ងង់ខ្លៅ ក្រាដក្រាមប្រដៅ ហៅបាកដិកស្រី
មេបាកាប់គេ ស្លាប់ពីស្លាប់ចី រំលួតកូនខ្ទី
ស្មើរំលាយព្រះ ៗ

មានកាលមិនក្សួយ ខ្ទិនជើងខ្ទិនដៃ កខ្ទះកខ្លាស
ខ្លាក់ក្លែកអន្ទការ អនិច្ចាប្រូណោស់ អាក្រក់កក្តិខ្លាស
ភកូនគេទៅ ៗ

២២០- អភោចឹស្បុសោយ សុសសព្វផល់ម្ដាយ ផល់ពូជពង្សផៅ
ស្លាប់ទៅនើទុក្ខ នរកហាន់ក្រៅ គេស្រុសទឹកក្ដៅ
ស្លាប់ទៅរស់ទៀត ៗ

ស៊ីខ្ទុះឈាមឯង ព្រះអង្គសម្ដែង ជាម៉ឺនសែនជាតិ
ទៀតមកជាប្រេត ហេតុកម្មមិនឃ្លាត អត់ឃ្លានគ្មានញាតិ
ហែកកូនឯងស៊ី ៗ

ព្រះពុទ្ធថ្លែងប្រោស ធម៌ថ្លែងសន្តោស សោយទុក្ខរ៉ាំរី
ហេតុចិត្តប្ញស្សា មិច្ឆាទិដ្ឋី កើតជាជ្រូកញី
គេគ្រៀវគេចាក់ ៗ

អសង្ខេយ្យឆ្នាំ ហេតុផលសេសកម្ម កើតជាមនុស្សខ្វាក់
មនុស្សខ្វិនព្រៃមព្រួម ជាគមជាពាក់ ខ្វើយឆ្កួតអបលក្ខណ៍
ជាស្អកឥតប្តី ៗ

បើម្ដាយជួយព្រួត　ជួយផាន់ល្បួត　រំលាយកូនខ្ញុំ
នរកប្រេតព្រមគ្នា　ម៉ងឃើញស្មើ　ដ្បិតចិត្តតិរិយ
ទាំងម្ដាយទាំងកូន ។

២២៥- ហេតុនេះគួរខ្លាច　ផម្ភតាតោរកាច　មិនកែលស្លាត់ស្លួរ
អាសោចកេរ្តិ៍ឈ្មោះ　ទាំងអស់បងប្អូន　ទេព្តាភាដួង
កាត់កាល់លែងរាប់ ។

គួរប្រុងតរិយា　កើតទាំងសាសនា　ហៅមហាមានភ័ក្ត្រ
ទាំងប្រុសទាំងស្រី　កុំបីឲ្យខ្លាច　គួរខំរៀនផ្គាប់
បរលោកលោកិយ ។

ឯខុសមិនគាប់　បើមិនរៀបរាប់　រាល់រូបប្រុសស្រី
គាប់ខុសនៅចិត្ត　ខុសគាប់នៅស្ដី　គំរប់ជាបី
ខុសត្រូវនៅកាយ ។

កូនប្រុសប្រព្រឹត្ត   ការកើតឲ្យជិត   គំនិតឲ្យឆ្ងាយ
កើតមកជាខ្មែរ   កុំប្រែកូនក្លាយ   ធម្មតាសប្បាយ
កាកែងឲ្យខុក ។

ឲ្យទោសទាស់ខែង   ទាស់តែម្នាក់ឯង   ដល់ម្ដាយឪពុក
រឹងរឿងទោស   មានតែពីមុខ   មួយទៅនរក
មួយនាលោកិយ ។

២៣០- ណោះគោទោសោ   កើតពីមោហោ   ពល់រូបប្រុសស្រី
គួរកាន់មេត្តា   កតញ្ញូខន្តី   នេះគឺបាលី
ទៅកាន់បរលោក ។

ពាក្យពិតប្រដៅ   ឲ្យអស់កូនទៅ   ប្រព្រឹត្តរៀនយក
កូនណាមិនរៀន   កូននឹងមានយោងហោក   នឹងធ្លាក់ជ្រុលជ្រក
ក្នុងបតុកបាយ ។

ធំស្រេចនៅស្ងួត សុខខ្លួនរហូត ដកបវែងឆ្ងាយ

ខន្តីអំណត់ សន្តត់ក្នុងកាយ ជាតិជនទាំងឡាយ

កប្រកាន់បាន ។

ចេះហើយមិនដឹង ចិត្តនៅម្នះរឹង ប្រឹងរកកម្មដ្ឋាន

រកធម៌មិនយល់ ខ្វិលខ្វល់ឈប់ខាន បន្ទោសបុរាណ

ជាន្នានទិសស្រ័យ ។

វិបាកនិងបុណ្យ មានចិត្តជាមុន មាត់ជាបច្ច័យ

នាំចុះនាំឡើង ពីជើងពីដៃ សន្សំសព្វថ្ងៃ

ឈ្មោះហៅសំណាង ។

២៣៤- កើតក្នុងលោកិយ កល់រូបប្រុសស្រី មានចិត្តជាអាង

កុសលអកុសល ប្រពញ្ញសងខាង រូបនៅតេងតាង

តែងតាមនៅមក

មគ្គផលសីលទាន បើល្ងង់ឲ្យរៀន បើគ្មានឲ្យរក
យល់ល្អសាធស្អាត សង្អាតជ្រៀតជ្រែក ជ្រើសរើសរៀនយក
រក្សារូបកាយ ។

នេះតែហៅច្បាប់ ជាទីសណ្តាប់ សន្តានទាំងឡាយ
កូនចៅប្រុសស្រី កុំបីឡើយណាយ សន្ធេមបរិយាយ
និច្ចិតតែថែងថប់ ។

អ្នកព្រះភិរម្យ គាថាប្រ៊ីយខ្ញុំ បង្គំម្រាមដប់
លើសលស់ត្ថាត្ថធី រំលងពុំគាប់ ពុំគួរសមសព្វ
សុំសសាយសេចក្តី ។

កាយកម្មវចីកម្ម ឈ្មោះច្បាប់បណ្តាំ កូនចៅប្រុសស្រី
ជាបរមត្ថក្រៅ មិនហៅបាលី បរលោកលោកិយ
ទាំងពីរកន្លែង ។

២៤០- បើលោកឯណា ចេះចាំធម៌អាថ៌ ប្រាកដជាក់ស្តែង
ឃើញខុសត្រង់ណា កុំថាជាល្បែង ដ្បិតពាក្យខ្ញុំតែង
ឲ្យក្មេងរាក័យ ។

មិនមែនកកេកួត កុំថាខ្ញុំអួត ប្រាជ្ញខ្ញុំវៃ
ឃើញមនុស្សវង្វេង ខ្ញុំតែងច្បាប់ថ្មី អស់អាថ៌សេចក្តី
ឯរំចប់ហោង ។